ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣០ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រ ការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- យោងកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល សម្រាប់នីតិកាលទី៥ នៃរដ្ឋសភា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា **នៅខេត្តរតនគិរី** ដែលមានសមាសភាពដូចខាងក្រោមៈ



www.pheakdeylaw.com

| | | |
|---|---|---|
| ១. ឯ.ឧ លី ធុជ | ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស | ប្រធាន |
| ២. ឯ.ឧ អ៊ឹក ប្រាជ្ញា | រដ្ឋលេខាធិការក្រសួងព័ត៌មាន | អនុប្រធាន |
| ៣. ឯ.ឧ គឹម សុវណ្ណ | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៤.ឯ.ឧ អ៊ុំ ស៊ីថុល | អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៥. ឯ.ឧ កែវ ពង្ស | អនុរដ្ឋលេខាធិការក្រសួងការពារជាតិ | សមាជិក |
| ៦. ឯ.ឧ ហេង វណ្ណសក្តិ | អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ៧. ឯ.ឧ សេក សុជាតិ | អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ៨. ឯ.ឧ សុខ វិសាល | អនុរដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ | សមាជិក |
| ៩. ឯ.ឧ ណុះ ស្លេះ | អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១០. តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | | សមាជិក |
| ១១. តំណាងក្រសួងបរិស្ថាន | | សមាជិក |
| ១២. តំណាងក្រសួងធនធានទឹក និងឧតុនិយម | | សមាជិក |
| ១៣. តំណាងក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | | សមាជិក |
| ១៤. តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន | | សមាជិក |
| ១៥. តំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | | សមាជិក |
| ១៦. តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | | សមាជិក |
| ១៧. តំណាងក្រសួងពាណិជ្ជកម្ម | | សមាជិក |
| ១៨. តំណាងក្រសួងកិច្ចការនារី | | សមាជិក |
| ១៩. តំណាងក្រសួងរ៉ែ និងថាមពល | | សមាជិក |
| ២០. តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | | សមាជិក |
| ២១. តំណាងក្រសួងអភិវឌ្ឍន៍ជនបទ | | សមាជិក |
| ២២. តំណាងក្រសួងឧស្សាហកម្ម និងសិប្បកម្ម | | សមាជិក |
| ២៣. តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | | សមាជិក |
| ២៤. តំណាងក្រសួងផែនការ | | សមាជិក |
| ២៥. តំណាងក្រសួងយុត្តិធម៌ | | សមាជិក |
| ២៦. តំណាងក្រសួងទេសចរណ៍ | | សមាជិក |
| ២៧. តំណាងក្រសួងធម្មការ និងសាសនា | | សមាជិក |
| ២៨. តំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងកីឡា | | សមាជិក |
| ២៩. តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | | សមាជិក |
| ៣០. តំណាងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | | សមាជិក |

**ប្រការ២.-**

អភិបាលនៃគណៈអភិបាលខេត្តត្រូវបានប្រគល់ភារកិច្ចជាអនុប្រធានអចិន្ត្រៃយ៍ក្រុមការងារថ្នាក់ជាតិប្រចាំខេត្តរបស់ខ្លួន។

តួនាទី ភារកិច្ច របៀបរបបការងាររបស់ក្រុមការងារត្រូវកំណត់ដោយសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា។

ប្រធានក្រុមការងារមានសិទ្ធិសម្របសម្រួលជាមួយក្រសួង ស្ថាប័ននានា ដើម្បីចាត់មន្ត្រីថ្នាក់អគ្គនាយក អគ្គនាយករង ឬមន្ត្រីថ្នាក់ប្រហាក់ប្រហែលឲ្យចូលរួមក្នុងក្រុមការងារនេះ។

**ប្រការ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានស្ថាប័ន រដ្ឋបាលខេត្តរតនគិរី និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល:*

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី*
- *គ្រប់ក្រសួង ស្ថាប័ន*
- *រដ្ឋបាលថ្នាក់ក្រោមជាតិ*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*



www.pheakdeylaw.com